# ក្រុមហ៊ុន ជីនវីន អ៊ិនដាសស្ទ្រី ( ខេមបូឌា ) ខូអិលធីឌី

GINWIN INDUSTRY ( CAMBODIA ) CO., LTD

## កិច្ចព្រមព្រៀង

ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល៦០ថ្ងៃ គឺ
ចាប់ពីថ្ងៃទី៩ ខែ មីនា ឆ្នាំ២០២១ ដល់ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ២០២១

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោងមួយ ល្ងាច មានកិច្ចប្រជុំមួយនៅ ក្រុមហ៊ុន ជីនវីន អ៊ិនដាសស្ទ្រី (ខេមបូឌា) ខូអិលធីឌី មានអាសយដ្ឋានស្ថិតនៅភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានចំនួនកម្មករសរុបចំនួន១៧៥៨នាក់ (ស្រី ១៦៨០នាក់)មាននាយកឈ្មោះ WANG MENGJIN ជនជាតិចិន ជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ដែលមានលោក MIAO XUENAN ជាតំណាងនាយកប្រចាំក្រុមហ៊ុនបានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតយៈពេល៦០ថ្ងៃ។

ជាកិច្ចចាប់ផ្តើមលោក MIAO XUENAN ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ដល់អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំថ្ងៃនេះ បន្ទាប់មកលោកប្រធាន អង្គប្រជុំមានមតិសម្របសម្រួលអំពី ករណីខាងលើ និងពន្យល់ពីមូលហេតុដោយសារតែក្រុមហ៊ុនគ្មានការបញ្ជាទិញ និងដោយសារម្ចាស់ទំនិញបានពន្យាពេលទិញទំនិញក្នុងអំឡុងពេលផ្ទុះមេរោគ ឆ្លងជាសាកលកូវីដ-១៩ ដូចនេះក្រុមហ៊ុន ជីនវីន អ៊ិនដាសស្ទ្រី (ខេមបូឌា) ខូអិលធីឌី និងកម្មករនិយោជិតទាំងអស់ បានព្រមព្រៀងគ្នាដូចខាងក្រោម:

១-ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន២៦២នាក់ (ស្រី២២៩នាក់) រយៈពេល៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី៩ ខែ មីនា ឆ្នាំ២០២១ ដល់ថ្ងៃទី៧ ខែ ឧសភា ឆ្នាំ២០២១ ។

២-ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះភាគីទាំងពីរបានឯកភាពអនុវត្តន៏តាមសេចក្តីណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ខេត្តកណ្តាលថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១

**បានឃើញនិងឯកភាព**

**តំណាងកម្មករនិយោជិត**


ជា ជួន


ជា ជួន


គីម ស៊ុនរី


ឃិន សុខា


ឃិន សុខា


អ៊ឹម គីមសួរ

**តំណាងក្រុមហ៊ុន**




Mr. Miao xuenan